ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៥៦ ....... សហវ.ប្រក

## ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនិងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣.អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤.អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើត "**ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនិងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ**" ដែលសរសេរអក្សរកាត់ថា "**ក.ប.ច.**" ដើម្បីធានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការគ្រប់គ្រង ការធានាកិច្ចដំណើរការរៀបចំ ការជំរុញវឌ្ឍនភាព និងការធ្វើសេចក្តីសម្រេចចិត្តលើការងារពាក់ព័ន្ធនឹងការងាររៀបចំគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (State Asset Register Management Information System - SARMIS) និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-tax Revenue Management Information System - NRMIS)។

**ប្រការ២.-**

**ក.ប.ច.** មានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| - ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.) | ប្រធាន |
| - ឯកឧត្តមបណ្ឌិត **គង់ ម៉ារី** អនុរដ្ឋលេខាធិការ ក.ស.ហ.វ. | អនុប្រធានប្រចាំការ |
| - ឯកឧត្តម **យ៉េត ទីណែល** អនុរដ្ឋលេខាធិការ ក.ស.ហ.វ. និងជាអគ្គលេខាធិការរងនៃ អ.ត.ហ. | អនុប្រធាន |
| - ឯកឧត្តម **ចាន់ ប៊ុនឥន្ទ្រាខុន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ | អនុប្រធាន |
| - ឯកឧត្តម **នេត មុន្នី** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ | អនុប្រធាន |
| - ឯកឧត្តម **ឈួន សំរិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល | អនុប្រធាន |
| - ឯកឧត្តម **ហ៊ីង ច័ន្ទបូរ៉ា** អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| - ឯកឧត្តម **ម៉ិញ ឆានសុវណ្ណអាទិច្ចារសីលា** អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| - ឯកឧត្តម **សៀក សុភ័គ** អគ្គនាយករងនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ | សមាជិក |

- លោក **ម៉ាន ប៊ុនណារិត** អគ្គនាយករង
  នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក
- លោក **គង់ ម៉ារីនម៉ូលីវ៉ា** អគ្គនាយករង
  នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក
- ឯកឧត្តម **អៀច សេដ្ឋា** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
  នៃអគ្គលេខាធិការដ្ឋាន ក.ស.ហ.វ. សមាជិក
- លោក **ម៉ែន ទុត្តា** ប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ
  នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក
- លោក **សុខ ឌី** ប្រធាននាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
  នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក
- លោក **ជា ទណ្ឌារ័ត្ន** ប្រធាននាយកដ្ឋានចំណូលថវិកា
  នៃអគ្គនាយកដ្ឋានរតនាគារជាតិ សមាជិក
- លោក **ម៉ម រិទ្ធី** ប្រធាននាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ
  នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក
- លោក **ណាំ ស៊ីនិត** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
  នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក
- លោក **ហ៊ត់ ឆានី** ប្រធាននាយកដ្ឋានចំណូលសាធារណៈ
  នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ សមាជិក។

**ប្រការ៣.-**

**គ.ប.ច.** មានភារកិច្ច ដូចខាងក្រោម÷

- ដឹកនាំ សម្របសម្រួល និងរៀបចំនិម្មាបនកម្ម ផែនទីមគ្គុទ្ទេសក៍ និងផែនការសកម្មភាព ដើម្បីអភិវឌ្ឍ ពង្រីក និងធ្វើសុវុឌ្ឍិកម្មគម្រោង SARMIS និង NRMIS ឱ្យក្លាយជាប្រព័ន្ធជាតិតែមួយ
- ដឹកនាំ សម្របសម្រួល និងរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់គាំទ្រដល់ការរៀបចំ ការអនុវត្ត ការពង្រីក និងការធ្វើសុវុឌ្ឍិកម្មគម្រោង SARMIS និង NRMIS
- ដឹកនាំរៀបចំការតម្រង់ទិសនីតិវិធីអនុវត្តការងារស្របតាមចក្ខុវិស័យនៃគម្រោង SARMIS និង NRMIS
- ដើរតួជាក្បាលម៉ាស៊ីនក្នុងការដឹកនាំការអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងការធ្វើបរិវត្តកម្ម ព្រមទាំងសហការ និង សម្របសម្រួលជាមួយនឹងតួអង្គពាក់ព័ន្ធ ក្នុងការពង្រឹងការចូលរួមប្រកបដោយស្មារតីបុរេសកម្ម សកម្ម និងទទួលខុសត្រូវខ្ពស់ក្នុងកិច្ចដំណើរការអនុវត្តគម្រោង SARMIS និង NRMIS

- ធានាភាពត្រឹមត្រូវ ភាពប្រកួតប្រជែង និងប្រសិទ្ធភាពនៃការដេញថ្លៃសម្រាប់ការទ្រទ្រង់ដល់ការរៀបចំការកសាង និងការដាក់ឱ្យដំណើរការគម្រោង SARMIS និង NRMIS
- សហការនិងសម្របសម្រួលជាមួយនឹងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ក្នុងការគាំទ្រកិច្ចដំណើរការអនុវត្តគម្រោង SARMIS និង NRMIS
- ដឹកនាំ សម្របសម្រួល និងរៀបចំផែនការបណ្តុះបណ្តាលនិងកសាងសមត្ថភាព ដើម្បីទ្រទ្រង់ដល់ការអនុវត្តគម្រោង SARMIS និង NRMIS
- កៀរគរអ្នកជំនាញ ទីប្រឹក្សា និងអ្នកបច្ចេកទេសជាតិនិងអន្តរជាតិដែលមានសមត្ថភាពនិងទេពកោសល្យ ដើម្បីអភិវឌ្ឍនិងនវានុវត្តគម្រោង SARMIS និង NRMIS
- ធ្វើទស្សនកិច្ចសិក្សាក្នុងបរិការណ៍តំបន់និងអន្តរជាតិ ដើម្បីសិក្សាអំពីម៉ូដែលនិងឧត្តមានុវត្តន៍អន្តរជាតិនៃការរៀបចំ ការអនុវត្ត ការពង្រីក និងការធ្វើសុក្រឹតកម្មគម្រោង SARMIS និង NRMIS
- ដឹកនាំ សិក្សា និងរៀបចំឱ្យមានការធ្វើសន្ទានកម្មទិន្នន័យរវាង SARMIS និង NRMIS ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀត
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាន **គ.ប.ច.**។

**ប្រការ៤.-**

អនុប្រធានប្រចាំការ អនុប្រធាន និងសមាជិក **គ.ប.ច.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ប.ច.**។

ក្នុងករណីអវត្តមានឬមានធុរៈ ប្រធាន **គ.ប.ច.** អាចប្រគល់សិទ្ធិជូនអនុប្រធានប្រចាំការឬអនុប្រធាន **គ.ប.ច.** ណាមួយឱ្យកោះអញ្ជើញនិងដឹកនាំកិច្ចប្រជុំ។

**ប្រការ៥.-**

**គ.ប.ច.** មានសិទ្ធិប្រើប្រាស់ត្រារបស់ **ក.ស.ហ.ទ.** នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៦.-**

**គ.ប.ច.** មានលេខាធិការដ្ឋានមួយជាសេនាធិការលើការងាររដ្ឋបាលនិងបច្ចេកទេស។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ប.ច.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី **ក.ស.ហ.ទ.**។

**ប្រការ៧.-**

សមាសភាព **គ.ប.ច.** និងលេខាធិការដ្ឋាន **គ.ប.ច.** ត្រូវទទួលបានការលើកទឹកចិត្ត ដូចខាងក្រោម÷

- ការលើកទឹកចិត្តផ្នែកលាភការពីមូលនិធិប្រាក់រង្វាន់របស់ **គ.ស.ហ.ទ.** តាមអត្រាដូចមានកំណត់ដោយការសម្រេចរបស់រដ្ឋមន្ត្រី **គ.ស.ហ.ទ.**។
- ប្រាក់ឧបត្ថម្ភមុខងារប្រចាំខែពីមូលនិធិរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬមូលនិធិប្រាក់រង្វាន់របស់ **គ.ស.ហ.ទ.** តាមសន្ទស្សន៍កំណត់ក្នុងប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៤។

**ប្រការ៨.-**

គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនិងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ អាចទទួលបានហិរញ្ញប្បទានគាំទ្រសម្រាប់ការអភិវឌ្ឍ ប្រតិបត្តិការនិងការគ្រប់គ្រងថែទាំពីប្រភពផ្សេងៗ ដែលជាផ្នែកមួយនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**ប្រការ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃ **គ.ស.ហ.ទ.** ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៥កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ